actionaid

# សេចក្តីសង្ខេបរបាយការណ៍ស្រាវជ្រាវស្តីពី

## "ភាពងាយរងគ្រោះរបស់ស្ត្រីមានពិការភាពទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ"

## គោលបំណង

របាយការណ៍នេះបានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវដែលបានធ្វើឡើងនៅខេត្តកំពត និងពោធិ៍សាត់ ដើម្បីកំណត់ស្វែងរកឧបសគ្គ និងភាពងាយរងគ្រោះនៃការធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ដែលស្ត្រី និងកុមារីបានជួបប្រទះ។ របាយការណ៍នេះផ្តល់អនុសាសន៍ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការធ្វើបរិយាបន្នស្ត្រីមានពិការភាពនៅក្នុងគម្រោងនៃភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## បរិបទ

ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើកសិផលិតកម្មដែលមានភាពរួសនឹងអាកាសធាតុ ប៉ុន្តែក៏មានភាពងាយរងគ្រោះខ្លាំងផងដែរដោយសារទឹកជំនន់តាមរដូវ គ្រោះរាំងស្ងួត និងការកើនឡើងនៃសីតុណ្ហភាព។ ប្រជាជនដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះបំផុត រួមបញ្ចូលទាំងជនមានពិការភាព គឺភាគច្រើនជាកសិផលិតករ។ ខេត្តកំពត និងពោធិ៍សាត់ ដែលជាទីតាំងនៃការស្រាវជ្រាវនេះ មានចំនួនជនមានពិការភាពខ្ពស់ (២២.៧៧១ និង ២១.១០៤) ដែលក្នុងនោះស្ត្រីមានពិការភាពមានប្រមាណ ៥៩% (ខេត្តកំពត) និង ៦១% (ខេត្តពោធិ៍សាត់) ។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវសម្រាប់ការស្រាវជ្រាវនេះរួមមានការសិក្សាឯកសារដែលមានស្រាប់ គោលនយោបាយ និងការសិក្សានានា កិច្ចសម្ភាសន៍ស៊ីជម្រៅជាមួយភាគីពាក់ពន្ធ័សំខាន់ៗ និងស្ត្រីដែលមានពិការភាព និងការពិភាក្សាជាក្រុមជាមួយស្ត្រីមានពិការភាព ដោយអនុវត្តលំហាត់ប្រកបដោយការចូលរួមមួយចំនួនរួមមាន ការធ្វើផែនទីធនធាន និងការកំណត់មុខសញ្ញាគ្រោះថ្នាក់ (resource and hazard mapping) ការធ្វើកាលប្បវត្តិ (historical timelines) ការបង្កើតទស្សនៈវិស័យ (Visioning) ការកំណត់តួអង្គ (Venn diagram) ប្រតិទិនរដូវកាល (seasonal calendar) ការធ្វើផែនទីមាទ្រីសនៃភាពងាយរងគ្រោះ និងការសម្រេចចិត្ត (matrix mapping of vulnerability and decision making) ។ ការធ្វើសិក្ខាសាលាពិគ្រោះយោបល់ពីចំងាយជាមួយអង្គការជនពិការ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការទៅលើបញ្ហាពិការភាព ត្រូវបានធ្វើឡើងដើម្បីបង្ហាញលទ្ធផលបឋម ផ្ទៀងផ្ទាត់លទ្ធផលនៃការសិក្សា ក៏ដូចជា ប្រមូលធាតុចូលបន្ថែមសម្រាប់ ផ្តល់អនុសាសន៍ និងបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ការសិក្សានេះ។

## លទ្ធផលនៃការសិក្សាសំខាន់ៗ៖

**មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុដែលអាចកើតមាន៖** ទឹកជំនន់តាមរដូវ ព្យុះ គ្រោះរាំងស្ងួត ការកើនឡើងសីតុណ្ហភាព ធាតុអាកាសធ្ងន់ធ្ងរ និងការហូរចូលទឹកប្រៃ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សន្តិសុខស្បៀង ការរស់នៅ និងសកម្មភាពសេដ្ឋកិច្ច សុខុមាលភាព និងសុខភាពរបស់ស្ត្រីមានពិការភាព ។

**ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើស្ត្រីមានពិការភាព៖** ការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់ស្ត្រីមានពិការភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយពួកគេងាយនឹងរងគ្រោះពីភាពគ្រោះថ្នាក់នានានៃអាកាសធាតុជាងក្រុមដែលងាយរងគ្រោះដទៃទៀត ពីព្រោះពួកគេភាគច្រើនមានគុណវិបត្តិខាងផ្នែករាងកាយ និងសុខភាពផ្លូវចិត្ត ហើយពួកគេមានការអប់រំ អំណាចសេដ្ឋកិច្ច និង ការសម្រេចចិត្តទាក់ទងនឹងការបន្សាំការប្រែប្រួលអាកាសធាតុតិចតួចបំផុត។

- **សន្តិសុខស្បៀង និងទឹក៖** ការផ្លាស់ប្តូររដូវកាល និងមានការផ្ទុះឡើងនូវកត្តាសត្វល្អិតចង្រៃ និងជំងឺទៅលើដំណាំនិងសត្វ(ដែលបណ្តាលមកពីធាតុអាកាសធ្ងន់ធ្ងរ) បានប៉ះពាល់ដល់ផលិតភាពរបស់ពួកគេ ដោយគំរាមកំហែងដល់សន្តិសុខស្បៀងរបស់ស្ត្រីមានពិការភាព។ ដើម្បីទទួលបានផលពីដំណាំ និងបង្កើនផលិតភាព ពួកគេបានប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិត និងជីគីមី ដែលបានបង្កើនថ្លៃដើមផលិតកម្ម និងប៉ះពាល់សុខភាពរបស់ពួកគេកាន់តែធ្ងន់ធ្ងរឡើង។ ធាតុអាកាសធ្ងន់ធ្ងរ និងគ្រោះរាំងស្ងួតបានកាត់បន្ថយលទ្ធភាពប្រើប្រាស់ទឹកស្អាត អនាម័យ និងកន្លែងអនាម័យ (WASH) សម្រាប់ស្ត្រីមានពិការភាព។ ពួកគេក៏បានរាយការណ៍ថាបានទិញទឹកសម្រាប់ប្រើប្រាស់ ឬត្រូវធ្វើដំណើរឆ្ងាយដើម្បីទៅដងទឹកមកប្រើប្រាស់ ឬត្រូវពឹងផ្អែកលើសមាជិកគ្រួសារ ដោយសារតែអណ្តូងនោះមិនបង្កលក្ខណៈងាយស្រួល ងតម្រូវការដល់ជនពិកា និងត្រូវបានសាងសង់ដោយ ដោយគ្មានបំពាក់ឧបករណ៍ជំនួយដើម្បីឆ្លើយតបទៅនឹងតម្រូវការជនមានពិការភាពនោះទេ។ ស្ត្រីមានពិការភាពត្រូវការប្រើប្រាស់ទឹកច្រើនជាងស្ត្រីធម្មតា ព្រោះពួកគេត្រូវការ សម្អាតឧបករណ៍ជំនួយ និងរក្សាអនាម័យរាងកាយ និងពេលមករដូវ។
- **ជីវភាពរស់នៅ និងសកម្មភាពសេដ្ឋកិច្ច៖** ទិន្នផលត្រីធម្មជាតិនៅក្នុងខេត្តទាំងពីរកំពុងធ្លាក់ចុះ ដោយសារការកាប់បំផ្លាញព្រៃឈើ គ្រោះរាំងស្ងួត និងការកើនឡើងកម្តៅដែលធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលគ្រួសាររបស់ប្រជានេសាទដែលចិញ្ចឹមជីវិតដោយពឹងផ្អែកទាំងស្រុងលើធនធានធម្មជាតិ។ កំឡុងពេលមានគ្រោះមហន្តរាយ ការរស់នៅរបស់ស្ត្រីមានពិការភាពមានការលំបាកខ្លាំង ដោយសារពួកគេពិបាករកប្រាក់ចំណូលប្រចាំថ្ងៃ។ ដូច្នេះពួកគេត្រូវពឹងផ្អែកទាំងស្រុងលើការផ្តល់ជំនួយសង្គ្រោះពីអាជ្ញាធរមូលដ្ឋាន ឬភ្នាក់ងារផ្សេងទៀត។

- **ការប្រើប្រាស់ធនធាន និងការគាំទ្រនានាប្រកបដោយសមធម៌៖** ស្ត្រីមានពិការភាពមិនទទួលបានការយកចិត្តទុកដាក់ ឬការគាំទ្រពិសេសណាមួយទៅលើការធ្វើឱ្យប្រសើរឡើងផ្នែកជីវភាពរស់នៅ និងមិនមានលទ្ធភាពប្រើប្រាស់ធនធានប្រកបដោយសមធម៌នៅក្នុងសហគមន៍របស់ពួកគេ។ ទោះបីជាពួកគេត្រូវបានចាត់ទុកជាក្រុមងាយរងគ្រោះដែលត្រូវផ្តល់អាទិភាពក្នុងកំឡុងពេលមានគ្រោះមហន្តរាយ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរក៏ដោយ ប៉ុន្តែមិនមានគោលការណ៍ណែនាំ និងកិច្ចអន្តរាគមន៍គាំទ្រណាមួយឡើយដើម្បីដោះស្រាយតម្រូវការពិសេសរបស់ពួកគេនោះទេ។ ការមិនមានបង្គន់អនាម័យ ជម្រាល បង្កាន់ដៃ និងបង្គោលដែលជាតម្រូវការមូលដ្ឋានចាំបាច់ក្នុងការប្រើប្រាស់និងជួយសម្រួល ឬបង្ហាញផ្លូវដល់ស្ត្រីមានបញ្ហាកំសោយគំហើញ និង និងពិការរាងកាយជាឧបសគ្គដ៏ធ្ងន់ធ្ងរសម្រាប់ពួកគេក្នុងការជម្លៀសទៅទីជម្រកសុវត្ថិភាពនៅពេលមានគ្រោះធម្មជាតិ។
- **បញ្ហាទាក់ទងនឹងសុខភាព៖** ក្រៅពីបញ្ហាសុខភាពដែលមនុស្សគ្រប់រូបប្រឈមមុខនៅពេលមានគ្រោះទឹកជំនន់ (ដូចជា ជំងឺរាគ គ្រុនក្តៅ ជំងឺស្បែក ភាពតានតឹង ស្រ្តេស) ស្ត្រីមានពិការភាពប្រឈមនឹងផលវិបាកផ្នែកសុខភាពបន្ថែមទៀតដោយសារតែភាពស្មុគស្មាញនានាដែលពាក់ព័ន្ធទៅនឹងបញ្ហាពិការភាពរបស់ពួកគេ។ ពួកគេជួបឧបសគ្គក្នុងការទទួលបានសេវាកម្មថែទាំសុខភាព និងព័ត៌មានសុខភាពសាធារណៈ ឬព័ត៌មានសង្គ្រោះបន្ទាន់ឱ្យបានទាន់ពេលវេលា និងស្ថិតនៅក្នុងទម្រង់ងាយស្រួលយល់សម្រាប់ពួកគេ។ ក្នុងករណីខ្លះ សេវាកម្មទាំងអស់នេះអាចនឹងមិនមាន ឬមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីមានពិការភាព។ ពួកគេក៏រងគ្រោះដោយសារជំងឺដែលទាក់ទងនឹងកំដៅដូចជា ឈឺក្បាលខ្លាំង អស់កម្លាំងល្ហិតល្ហៃ ភាពមិនប្រក្រតីនៃការគេង និងការបរិភោគអាហារ និងការប្រកាច់ ដែលនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពភាពផ្លូវចិត្ត និងផ្លូវកាយ ដែលរួមបញ្ចូលទាំង អារម្មណ៍ កម្លាំងថាមពល និងសមត្ថភាពក្នុងការដោះស្រាយភាពតានតឹងជាដើម។ ពួកគេបានប្រឈមមុខនឹងភាពលំបាកក្នុងការរក្សាអនាម័យរាងកាយនិងពេលមករដូវក្នុងកំឡុងពេលមានការកើនឡើងកម្តៅខ្លាំង និងគ្រោះរាំងស្ងួត។

**យុទ្ធសាស្ត្រដោះស្រាយ៖** ការផ្លាស់ប្តូរការនេសាទ និងការធ្វើកសិកម្ម ត្រូវបានរកឃើញនៅក្នុងការសិក្សានេះ ជាឧទាហរណ៍ស្ត្រីដែលមានពិការភាពបានរាយការណ៍ថាបានប្រើប្រាស់ពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួត ឬផ្លាស់ប្តូរពូជដំណាំ ឬទិញឧបករណ៍ធន់នឹងព្យុះសម្រាប់ការនេសាទ។ ស្ត្រីខ្លះបានរាយការណ៍ថាគ្រួសាររបស់ពួកគេបានរៀនអំពីរបៀបផ្តល់ថ្នាំ និងចាក់វ៉ាក់សាំងដល់សត្វចិញ្ចឹមដើម្បីឆ្លើយតបទៅនឹងការទប់ស្កាត់ជំងឺបសុសត្វដែលបានផ្ទុះឡើង សង់ជម្រកដ៏រឹងមាំសម្រាប់សត្វជ្រកពេលកើនឡើងកម្តៅ និងសម្អាតជម្រកឱ្យបានញឹកញាប់។ ការជំពាក់បំណុល ការធ្វើពិពិធកម្មប្រាក់ចំណូល និង ចំណាកស្រុក គឺជាយុទ្ធសាស្ត្រដោះស្រាយចម្បងរបស់ពួកគេដើម្បីរកប្រាក់ចំណូលបន្ថែម ដែលពួកគេបានបាត់បង់ពីសកម្មភាពកសិកម្ម។

**អន្តរាគមន៍គាំទ្រដែលមានស្រាប់៖** អជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយនៅទីសាធារណៈ ផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ភ្លាមៗ និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសលើវិស័យកសិកម្ម (ការដាំដុះស្រូវ និងបន្លែ និងការចិញ្ចឹមសត្វ) ជាពិសេសការសាងសង់ ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាប្រឡាយ អណ្តូងទឹកសហគមន៍ និងផ្លូវថ្នល់ដើម្បីជួយសម្រួលដល់ការទទួលបានសេវាកម្ម និងទីផ្សារ។ នៅក្នុងទីតាំងដែលបានសិក្សា អង្គការក្រៅរដ្ឋាភិបាលតិចតួចណាស់ ដែលបានផ្តល់អន្តរាគមន៍ដោយផ្ទាល់ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅដល់ជនដែលមានពិការភាព ដោយសារតែពួកគេខ្វះ ជំនាញក្នុងការធ្វើការជាមួយពួកគេ និងមានថវិកាមានកម្រិតដើម្បីឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់ពួកគេ។ ផ្ទុយទៅវិញ អាណត្តិសំខាន់របស់អង្គការជនពិការភាគច្រើន គឺផ្តោតជាចម្បងទៅលើការលើកកម្ពស់សិទ្ធិរបស់ជនដែលមានពិការភាព ផ្តល់សេវាកម្មស្តារនីតិសម្បទា និង លទ្ធភាពទទួលបានការងារស្មើភាពគ្នា (ការពង្រឹងអំណាចសេដ្ឋកិច្ច)។ ពួកគេភាគច្រើនមានចំណេះដឹងតិចតួចស្តីពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ។

**អំណាចនៃការសម្រេចចិត្ត៖** ស្ត្រីដែលមានពិការភាពមានអំណាចតិចតួចក្នុងការបង្ហាញពីក្តីកង្វល់របស់ពួកគេ និងជះឥទ្ធិពលដល់ការសម្រេចចិត្តនានា នៅពេលដែលពួកគេមានការអប់រំតិចតួច និងមិនសូវមានអំណាចសេដ្ឋកិច្ច។ ដូច្នេះហើយទើបស្ត្រីដែលមានពិការភាពមិនត្រូវបានលើកទឹកចិត្ត ក្នុងដំណើរការសម្រេចចិត្តរបស់គ្រួសារទេ។ ពួកគេក៏ដើរតួនាទីបន្ទាប់បន្សំនៅក្នុងការសម្រេចចិត្តរបស់គ្រួសារ និងផ្តល់អំណាចដល់បុរស ដែលជាទូទៅបុរសគ្រប់ដណ្តប់ទៅលើការសម្រេចចិត្ត និងជាអ្នកសម្រេចចិត្តចុងក្រោយទៅលើរឿងដែលសំខាន់ៗពាក់ព័ន្ធនឹងសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ដោយសារតែមានឧបសគ្គផ្នែកទំនាក់ទំនង និងរាងកាយ ពួកគេតែងតែនៅដាច់ដោយឡែក មិនចូលរួមសកម្មភាពសហគមន៍ និងមិនត្រូវបានដាក់បញ្ចូលក្នុងការចូលរួមក្នុងដំណើរការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍ ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងអន្តរាគមន៍បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ លើសពីនេះទៅទៀត ស្ត្រីមានពិការភាពខ្វះអ្នកតំណាងជាស្ត្រីពិការដែលមានភាពជាអ្នកដឹកនាំ និងអំណាចក្នុងការសម្រេចចិត្តដើម្បីឱ្យអាជ្ញាធរមូលដ្ឋានបានដឹងលើពីការព្រួយបារម្ភរបស់ពួកគេ។ នៅពេលបុរសមានអំណាចក្នុងការសម្រេចចិត្តទាំងអស់ ហើយមានការយល់ដឹងតិចតួចអំពីតម្រូវការរបស់ស្ត្រីជាពិសេសស្ត្រីមានពិការភាព នេះអាចធ្វើឱ្យភាពងាយរងគ្រោះដល់ស្ត្រីកាន់តែធ្ងន់ធ្ងរឡើងចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**បុគ្គលមានឥទ្ធិពលនិងកត្តាជំរុញសំខាន់ៗ៖** កត្តាជំរុញដ៏សំខាន់ដែលលើកទឹកចិត្តឱ្យ ស្ត្រីដែលមានពិការភាពចាត់វិធានការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរួមមាន៖ ១)ធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារជាពិសេសជីវភាពរស់នៅ និងសន្តិសុខសេដ្ឋកិច្ច ២)ការទទួលបានសុខភាពល្អ ជាពិសេសគឺកូនៗ និង

គ្រួសារ និង ៣)ផ្តល់ការអប់រំល្អដល់កូនៗរបស់ពួកគេ ដើម្បីឱ្យពួកគេមានអនាគតល្អប្រសើរ។ មេភូមិ មេឃុំ និងក្រុមប្រឹក្សាឃុំគឺជាអ្នកមានឥទ្ធិពលដ៏មានសក្តានុពល ដែលស្ត្រីមានពិការភាពជឿទុកចិត្ត និងអាចទទួលព័ត៌មាន និងជំនួយសង្គ្រោះទាក់ទងនឹងគ្រោះមហន្តរាយ។ ស្ត្រីមានពិការភាពដែលមានតួនាទីដឹកនាំ ឬក៏មានអំណាចក្នុងការសម្រេចចិត្ត គឺជាអ្នកមានឥទ្ធិពលដ៏សំខាន់ក្នុងការពង្រឹងទំនុកចិត្តទៅលើ ខ្លួនឯងចំពោះស្ត្រីមានពិការភាពដទៃទៀត និងធ្វើជាតំណាងឱ្យសំឡេង និងកង្វល់របស់ពួកគេ។ ពួកគេបានរាយការណ៍ថាចូលចិត្តការប្រាស្រ័យទាក់ទងជួបមុខគ្នាដោយផ្ទាល់ ចូលរួមពិភាក្សាក្រុមតូច និងប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយគ្រួសារ ឬអ្នកថែទាំរបស់ពួកគេដើម្បីទទួលបានព័ត៌មាន ដែលមានប្រយោជន៍ទាក់ទងនឹងការបន្សាំការប្រែប្រួលអាកាសធាតុ។

**ឧបសគ្គសំខាន់ៗសម្រាប់ការបន្សាំការប្រែប្រួលអាកាសធាតុ៖** ដោយសារមានឧបសគ្គផ្នែករាងកាយ ផ្នែកអាកប្បកិរិយា ផ្នែកទំនាក់ទំនង និងផ្នែកសង្គម ស្ត្រីមានពិការភាពតែងតែត្រូវបានគេដាក់ដាច់ដោយឡែក និងមិនត្រូវបានរាប់បញ្ចូលទៅក្នុងការបញ្ចេញកង្វល់របស់ពួកគេ និងចូលរួមក្នុងដំណើរការសម្រេចចិត្តទាក់ទងនឹងអន្តរាគមន៍ការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍នោះទេ។

- **ឧបសគ្គផ្នែករាងកាយ៖** ស្ត្រីមានពិការភាព ស្ទើរមិនត្រូវបានដាក់បញ្ចូលក្នុងការធ្វើផែនការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទេ ដោយសារតែទីតាំងដែលត្រូវចូលរួមមិនបានផ្តល់លក្ខណៈងាយស្រួល និងឧបករណ៍ជំនួយសម្រាប់ជនមានពិការភាពផ្នែករាងកាយ និងកំសោយគំហើយ។ លើសពីនេះទៅទៀត វិធានការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយនានាមិនសូវបានគិតគូរដល់បញ្ហា និងតម្រូវការចាំបាច់សម្រាប់ជនមានពិការភាពប្រកបដោយប្រសិទ្ធភាពនោះទេ។ ពួកគេក៏មានការលំបាកក្នុងការជម្លៀសទៅទីជម្រកមានសុវត្ថិភាព និងការទទួលបានព័ត៌មានសំខាន់ៗក្នុងគ្រាអាសន្ន។ ពួកគេបានជួបនូវការរាំងស្ទះ ដោយសារការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ដែលរាំងដល់ការផ្លាស់ទីរបស់ពួកគេ ហើយពួកគេក៏បានបាត់បង់ឧបករណ៍ជំនួយក្នុងពេលមានទឹកជំនន់ ឬព្យុះ។
- **ឧបសគ្គផ្នែកព័ត៌មាន និងការប្រាស្រ័យទាក់ទង៖** កង្វះការបកស្រាយភាសាសញ្ញា ឧបករណ៍ជំនួយក្នុងការស្តាប់ ឬអក្សរស្ទាប ឬអក្សរពុម្ពធំៗបានរារាំងស្ត្រីមានពិការភាពក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ និងទទួលបានព័ត៌មានចាំបាច់ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយភាគច្រើនធ្វើឡើងតាមរយៈការប្រាស្រ័យទាក់ទងផ្ទាល់មាត់ និងចែករំលែកព័ត៌មានសំខាន់ៗនានាតាមរយៈគ្រួសារ ឬអ្នកថែទាំផ្ទាល់របស់ពួកគេ ច្រើនជាងការធ្វើការផ្ទាល់ជាមួយស្ត្រីមានពិការភាព។
- **ឧបសគ្គផ្នែកអាកប្បកិរិយា៖** ទស្សនៈអវិជ្ជមាន និងការមិនឲ្យតម្លៃដល់ជនដែលមានពិការភាព អាចនាំឱ្យក្លាយជាទម្រង់នៃការរើសអើងទៅលើជនមានពិការភាព ដែលអាចធ្វើឲ្យតាក់តែង គោលនយោបាយ និង

ការអនុវត្តអន្តរាគមន៍នានាទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ។ បញ្ហាទាំងនេះ បានបង្កើតជាឧបសគ្គផ្នែករាងកាយ ផ្នែកព័ត៌មាន និងការប្រាស្រ័យទាក់ទង និងឧបសគ្គផ្សេងទៀត។ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងសហគមន៍អំពីបញ្ហាពិការភាព និងសិទ្ធិរបស់ពួកគេនៅមានកម្រិតនៅឡើយ។ ការយល់ឃើញបែបនេះមិនមែនត្រឹមតែពីអ្នកដទៃនោះទេ សូម្បីតែស្ត្រីមានពិការភាពខ្លួនឯងក៏មិនសូវឲ្យតម្លៃចំពោះខ្លួនឯងផងដែរ។

- **ឧបសគ្គធនធានៈ** ស្ត្រីមានពិការភាពភាគច្រើនមានអំណាចសេដ្ឋកិច្ចតិចតួច ដោយសារពួកគេគ្មានការងារជាប់លាប់ ខ្វះប្រាក់ចំណូលដែលគួរឲ្យទុកចិត្ត ឬធនធានហិរញ្ញវត្ថុដើម្បីទប់ទល់ និងស្តារជីវភាពឡើងវិញនៅពេលទទួលរងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុ។ ស្ត្រីមានពិការភាពដែលមានការអប់រំតិច និងការងារមិនជាប់លាប់ ជាទូទៅមិនសូវមានអំណាចសេដ្ឋកិច្ច និងត្រូវពឹងផ្អែកលើគ្រួសាររបស់ពួកគេ ដែលបង្កជាហានិភ័យដល់ការរើសអើង អំពើហឹង្សាក្នុងគ្រួសារ និងប៉ះពាល់អវិជ្ជមានដល់សមត្ថភាពរបស់ពួកគេក្នុងការធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ កង្វះសម្ភារៈ និង ហិរញ្ញវត្ថុដែលចំបាច់ ដើម្បីប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុគឺជាឧបសគ្គចម្បងសម្រាប់ស្ត្រីមានពិការភាព ដោយសារពួកគេមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ មានកម្រិត។

## សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ស្ត្រីមានពិការភាពជួបគុណវិបត្តិ និងភាពងាយរងគ្រោះ បណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយច្រើនជាងស្ត្រីមិនមានពិការភាពនៅក្នុងសហគមន៍របស់ពួកគេ។ ការកាត់បន្ថយ និងវិធានការដោះស្រាយក្នុងរយៈពេលខ្លីមួយចំនួនត្រូវបានប្រើប្រាស់ ប៉ុន្តែមានវិសាលភាពតិចតួចណាស់។ ដោយសារឧបសគ្គផ្នែករាងកាយ ផ្នែកអាកប្បកិរិយា ការប្រាស្រ័យទាក់ទង និងឧបសគ្គកផ្នែកសង្គម លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ត្រីមានពិការភាពតែងតែនៅដាច់ដោយឡែក និងមិនត្រូវបានដាក់បញ្ចូលក្នុងការបញ្ចេញមតិយោបល់ បង្ហាញក្តីកង្វល់របស់ពួកគេ និងចូលរួមដំណើរការសម្រេចចិត្តទាក់ទងនឹងអន្តរាគមន៍នៃការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍។ ការស្រាវជ្រាវក៏បានបង្ហាញផងដែរថា ស្ត្រីមានពិការភាព ភាគច្រើនជាអ្នកទទួលផលដោយប្រយោលពីគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានា។ លើសពីនេះ អង្គការក្រៅរដ្ឋាភិបាលនិងអាជ្ញាធរមូលដ្ឋានភាគច្រើនមានការយល់ដឹងតិចតួចអំពីការធ្វើបរិយាបន្នពិការភាព និងមានធនធាន មានកំណត់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជនមានពិការភាព។

### អនុសាសន៍៖

**ការអនុវត្តកម្មវិធី៖**

- ប្រើប្រាស់វិធីសាស្ត្រធ្វីនត្រាក(Twin Track) ទៅលើកម្មវិធីទាំងអស់ដើម្បីបញ្ជ្រាបការធ្វើបរិយាបន្នពិការភាពនៅក្នុងសកម្មភាពទាំងអស់ និងផ្តល់នូវអន្តរាគមន៍ពិសេសទៅតាមបញ្ហាជាក់លាក់នៅក្នុងតំបន់។ វិធីសាស្ត្ររួមគ្នានេះនឹងបង្កើនការជះឥទ្ធិពលទៅលើអន្តរាគមន៍នានានៅក្នុងគម្រោង។
- បញ្ជ្រាបតម្រូវការរបស់ស្ត្រីមានពិការភាព ទៅក្នុងអន្តរាគមន៍នានានៃការបន្សាំទៅនឹងងការប្រែប្រួលអាកាសធាតុ និងការការពារគ្រោះមហន្តរាយទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងការការពារ ការកាត់បន្ថយ ការត្រៀមបង្ការ និងកម្មវិធីផ្តល់ជំនួយសង្គ្រោះបន្ទាន់។
- ប្រើប្រាស់ការតស៊ូមតិដោយផ្អែកលើភស្តុតាងដើម្បីធានាការដាក់បញ្ចូលជនមានពិការភាពនៅក្នុងអន្តរាគមន៍នានារបស់រដ្ឋាភិបាល និងរបស់អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាធានាឲ្យមានការអនុវត្តស្តង់ដាដែលបង្កលក្ខណៈងាយស្រួលនិងឆ្លើយតបទៅនឹងតម្រូវការជនមានពិការភាព ត្រូវបានអនុវត្តនៅក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ នានា។
- ពង្រឹងសមត្ថភាពក្រុមស្ត្រីដែលមានស្រាប់ក្នុងការគៀងគរធនធាន និងការតស៊ូមតិក្នុងការបែងចែកថវិការដើម្បីដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងអន្តរាគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។
- ផ្តល់អំណាចដល់ក្រុមដែលងាយនឹងជួបហានិភ័យ ជាពិសេសស្ត្រីដែលមានពិការភាព។
- កែសម្រួលកម្មវិធីបណ្តុះបណ្តាល និងឧបករណ៍ទំនាក់ទំនង និងសម្ភារៈផ្សេងៗដែលឮគិតគូរពីតម្រូវការពិសេស និងផ្តល់ភាពងាយស្រួលដល់ស្ត្រីមានពិការភាព
- ផ្តល់នូវអន្តរាគមន៍គ្រប់ជ្រុងជ្រោយ។
- បង្កើនភាពជាអ្នកដឹកនាំរបស់ស្ត្រីមានពិការភាពព និងធានាឱ្យមានអ្នកតំណាងស្ត្រីមានពិការភាពនៅកម្រិតថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ។

**យុទ្ធសាស្ត្រទំនាក់ទំនង៖**

- ប្រើប្រាស់វេទិកាប្រាស្រ័យទាក់ទង ដែលមានស្រាប់
- ធានាថាការប្រាស្រ័យទាក់ទងបង្កលក្ខណៈងាយស្រួលនិងឆ្លើយតបទៅនឹងតម្រូវការរបស់ជនដែលមានពិការភាពផ្សេងៗគ្នា
- ប្រើប្រាស់អ្នកមានឥទ្ធិពល ឬបុគ្គលគំរូក្នុងសហគមន៍
- បង្កើតភាពជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល (ជាពិសេសអង្គការជនពិការ) ដើម្បីផលិតសម្ភារៈទំនាក់ទំនង ដែលមានគុណភាពខ្ពស់នៅក្នុងទម្រង់ផ្សេងៗគ្នា
- បង្កើតទំនាក់ទំនងជាយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ការយល់ដឹងអំពីពិការភាពដើម្បីដោះស្រាយឧបសគ្គផ្នែកអាកប្បកិរិយា និងការមាក់ងាយទៅលើជនមានពិការភាព៕